**មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)**

ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ ១១១៨ ទូរស័ព្ទ: ៨៥៥-២៣-៨៨០ ៩១៦ ទូរសារ: ៨៥៥-២៣-៨៨៥ ១៤៦

# សេចក្តីប្រកាសព័ត៌មាន

*Released September 08, 2009*

## ស្វាគមន៍ចំពោះការបញ្ចុះអត្រាការប្រាក់របស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ។ សេដាក បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍សង្គមកម្ពុជាមួយដែលកសិករមានជីវិតរស់នៅប្រកបដោយភាពសប្បាយរីករាយ មានការសហការ និងជួយគ្នាទៅវិញទៅមក មានសិទ្ធិ និងអំណាចក្នុងការកំណត់នូវជោគវាសនារបស់ខ្លួន និងព្រមទាំងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ស្បៀងអាហារប្រកបដោយផាសុខភាពដល់សង្គមជាតិទាំងមូល។

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) និង បណ្តាញកសិករ និងធម្មជាតិ សូមធ្វើការស្វាគមន៍ និងគាំទ្រចំពោះនិន្នាការបញ្ចុះអត្រាការប្រាក់របស់បណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ យោងតាមការចុះផ្សាយរបស់កាសែតក្នុងស្រុកមួយចំនួននាពេលថ្មីៗនេះឱ្យដឹងថា ស្ថាប័នមីក្រូហិរញ្ញវត្ថុនឹងបញ្ចុះអត្រាការប្រាក់បន្ថែមទៀតពី ០.២ ភាគរយ ទៅ ០.៥ ភាគរយក្នុងមួយខែ។

បណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការ សេដាក មានប្រសាសន៍ថា វាគឺជាជំហានដ៏ល្អមួយជួយដល់កសិករក្នុងការធ្វើផលិតកម្មកសិកម្មរបស់ខ្លួនបានផលចំណេញ។ អត្រាការប្រាក់ខ្ពស់របស់ឥណទាននាពេលកន្លងមក គឺជាបញ្ហាប្រឈមដ៏ចំបងមួយរបស់កសិករ ដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរវិនិយោគលើការផលិតកម្មកសិកម្មរបស់ពួកគាត់។ លើសពីនេះទៅទៀត អត្រាការប្រាក់ខ្ពស់ធ្វើឱ្យកសិករខ្មែរពិបាកក្នុងការរបក្ខតប្រជែងបានជាមួយនឹងកសិករប្រទេសជិតខាង។ លោកបណ្ឌិតបន្ថែមថា ដើម្បីឱ្យ កសិករអាចផលិតបានចំណេញ ទាល់តែអត្រាការប្រាក់មានត្រឹមប្រហែល ១ភាគរយក្នុងមួយខែ។ លោកបណ្ឌិតក៏សុំអំពាវនាវឱ្យកសិករយើង ចូលរួមចលនាសន្សំប្រាក់ឱ្យបានច្រើន ដែលជាយុទ្ធសាស្ត្រមួយក្នុងការបង្កើនទុនក្នុងស្រុក ហើយធ្វើឱ្យអត្រាការប្រាក់ចុះទាបនៅពេលខាងមុខ។

លោក អ៊ួន សុផល ប្រធានបណ្តាញកសិករ និងធម្មជាតិ (FNN) មានប្រសាសន៍ថា វាគឺជាការល្អសំរាប់កសិករនៅពេលដែល ស្ថាប័នមីក្រូហិរញ្ញវត្ថុបញ្ចុះអត្រាការប្រាក់ ហើយថាកសិករនឹងមានលទ្ធភាពកាន់តែច្រើនថែមទៀតក្នុងការខ្ចីទុនទៅវិនិយោគ ពង្រីកមុខរបរកសិកម្មរបស់ពួកគាត់បន្ថែមទៀតដូចជា ការចិញ្ចឹមសត្វ និងដាំដំណាំបន្លែចំរុះជាដើម។ល។ លោក អ៊ួន សុផល បន្តថា កន្លងមកកសិករមួយចំនួនបានទៅខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុជាមួយនឹងអត្រាការប្រាក់ ៣ ភាគរយក្នុងមួយខែ ហើយមិនមានលទ្ធភាពសងប្រាក់វិញ បានបង្ខំចិត្តលក់គោ ក្របី និងដីធ្លីដើម្បីសង ធ្វើឱ្យជីវភាពកាន់តែក្រលំបាកថែមទៀត។ ជំនួសពីការទៅខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងនោះ កសិករខ្លះសុខចិត្តទុកដីទំនេរចោល (ដោយសារខ្វះទុនវិនិយោគ) និង បានទៅស៊ីឈ្នួលលក់កំលាំងពលកម្មឱ្យគេ និងអ្នកខ្លះសុខចិត្តធ្វើចំណាកស្រុកទៅក្រៅប្រទេសជាដើម។

**ទំនាក់ទំនង:** សម្រាប់ព័តិមានបន្ថែមសូមទំនាក់ទំនង:

| | | |
|---|---|---|
| បណ្ឌិត យ៉ង សាំងកុមារ | ប្រធានអង្គការ សេដាក | ទូរស័ព្ទ ០១២ ៨០២២០១ |
| លោក អ៊ួន សុផល | ប្រធានបណ្តាញកសិករ និងធម្មជាតិ | ទូរស័ព្ទ ០១២ ៥២៨៣០៥ |
| លោក ហ៊ឹម ខទៀត | មន្ត្រីទំនាក់ទំនងព័តិមាន អង្គការ សេដាក | ទូរស័ព្ទ ០១៦ ៥៧៥៧១៣ |